ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ៤៨៣ ព.ណ. ភ.ណ.ប

ភ្នំពេញ, ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៥

# សេចក្តីជូនដំណឹង

អនុលោមតាមច្បាប់ ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីការអនុវត្តច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ដើម្បីពង្រឹងក្នុងការផ្តល់សេវាឲ្យកាន់តែរហ័ស និងប្រកបដោយប្រសិទ្ធិភាពខ្ពស់ ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជូនដំណឹងដល់សាធារណជន និងភ្នាក់ងារតំណាងស្របច្បាប់ នៃម្ចាស់ម៉ាកទាំងអស់ ដែលទទួលបានគោលការណ៍ឯកភាពក្នុងការចុះបញ្ជីម៉ាករួចហើយ អញ្ជើញមកបង់សេវាចុះបញ្ជីម៉ាក ដោយផ្អែកតាមប្រកាសរួមលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៤ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ឲ្យបានមុនថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៥ ជាកំហិត ។

ក្នុងករណី លោក លោកស្រី ខកខានមិនបានអញ្ជើញមកបង់សេវាសុំចុះបញ្ជីម៉ាកបានទាន់ពេលវេលាតាមការកំណត់ខាងលើនេះទេ ក្រសួងពាណិជ្ជកម្មចាត់ទុកថា លោក លោកស្រី បានបោះបង់ចោលពាក្យស្នើសុំចុះបញ្ជីម៉ាករបស់ខ្លួន ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជ្រាបជាព័ត៌មាន ។

ក្រសួងពាណិជ្ជកម្ម